# រក្សាវាឲ្យបានស្អាតសំរាប់ទីវាលដាំបន្លែ

## ជំរើសដទៃទៀតនៃការគ្រប់គ្រងលើចំការ ដើម្បីកាត់បន្ថយសត្វចង្រៃ

Virginia Brunton & Jeremy Badgery-Parker, Ourimbah

### ការដាក់ឲ្យនៅដាច់ពីគេដើម្បីបង្ការកុំឲ្យឆ្លងរោគ

ក្រោយពេលដាក់ទុនពេលវេលា និងប្រាក់កាសក្នុងការបោសសំអាតចំការរបស់លោកអ្នក និងប្រតិបត្តិការអនុវត្តន៍ដើម្បីធ្វើឲ្យសត្វចង្រៃពិបាកចូលមក វាក៏ជាការសំខាន់ចាំបាច់ផងដែរ ដែលហានិភ័យនៃការនាំយកសត្វល្អិតចង្រៃ និងជម្ងឺចូលមក ធ្វើឲ្យមានតិចបំផុត។ រឿងនេះធ្វើឲ្យការដាក់ឲ្យនៅដាច់ពីគេដើម្បីបង្ការកុំឲ្យឆ្លងរោគ និងការហាមមិនឲ្យចូលក្នុងកន្លែងមានសារៈសំខាន់បំផុត។ ចំណុចឆែកឆេរ និងត្រួតពិនិត្យត្រូវបានគេសម្គាល់ដឹងថាជាផ្នែកនៃចំការដែលគេរៀបចំឲ្យទៅជាមូលដ្ឋានសម្រាប់បណ្តេញសត្វចង្រៃចេញ។

សូមធ្វើអ្វីៗគ្រប់យ៉ាងដែលលោកអ្នកអាចធ្វើបាន ដើម្បីកាត់បន្ថយលទ្ធភាពកុំឲ្យមានអ្នកណាម្នាក់ ឬវត្ថុណាមួយចូលក្នុងដំណាំរបស់លោកអ្នក អាចនាំយកចូលជាមួយនូវសត្វល្អិតចង្រៃ ព្រូន ជម្ងឺ ឬគ្រាប់ពូជរបស់រុក្ខជាតិតូចៗឥតប្រយោជន៍។ វត្ថុទាំងអស់ដែលចូលទៅក្នុងតំបន់ “ ស្អាត ” និងក្នុងកន្លែងផលិតភោគផល ត្រូវតែបានឆែកមើល បោសសំអាត ហើយបើជាការចាំបាច់ ត្រូវសម្លាប់មេរោគជាមុនសិន។ លោកអ្នកចាំបាច់ត្រូវប្រុងប្រយ័ត្ន ជាពិសេសជាមួយនឹងរបស់របរដែលពុំថ្មី។ ប្រសិនបើលោកអ្នកកំពុងប្រើឡើងវិញនូវវត្ថុណាមួយ ដែលធ្លាប់បានប្រើជាមួយដំណាំមុនៗ វត្ថុនោះត្រូវតែបានលាងសំអាត និងសម្លាប់មេរោគឲ្យបានល្អ។

### ការដាក់វត្ថុនាំចូលមកក្នុងប្រទេសអូស្ត្រាលីឲ្យនៅដាច់ពីគេដើម្បីបង្ការកុំឲ្យ ឆ្លងរោគ

ប្រទេសអូស្ត្រាលីមានច្បាប់ដាក់វត្ថុនាំចូលឲ្យនៅដាច់ពីគេយ៉ាងតឹងរ៉ឹង។ ការនេះគឺដើម្បីការពារកុំឲ្យរុក្ខជាតិ និងសត្វចង្រៃ និងជម្ងឺចូលមកក្នុងប្រទេសអូស្ត្រាលីបាន។ គឺជាការខុសច្បាប់ដែលនាំយកបំណែករុក្ខជាតិណាមួយ ការនេះរាប់បញ្ចូលទាំងគ្រាប់ពូជផងដែរ ចូលមកក្នុងប្រទេសអូស្ត្រាលីដោយពុំបានប្រកាសប្រាប់អំពីវត្ថុទាំងនេះ និងឲ្យគេពិនិត្យវាជាមុនសិន។ ជម្ងឺថ្មីៗជាច្រើនក្នុងប្រទេសអូស្ត្រាលីបានមកពីការនាំចូលដោយខុសច្បាប់។ ការខូចខាតទៅលើឧស្សាហកម្មអាចធ្ងន់ធ្ងរ ហើយការផាកពិន័យក៏ច្រើនដែរ។

### ការដាក់កូនរុក្ខជាតិតូចៗក្នុងស្រុកឲ្យនៅដាច់ពីគេដើម្បីបង្ការកុំឲ្យឆ្លងរោគ

ប្រសិនបើទិញកូនរុក្ខជាតិតូចៗ ចូរពិនិត្យវានៅពេលគេប្រគល់ឲ្យ បើរុក្ខជាតិណាមួយមានរោគសញ្ញានៃជម្ងឺ ឬសត្វល្អិតចង្រៃ ចូរប្រាប់អ្នកប្រគល់ឲ្យ និងអ្នកផ្គត់ផ្គង់ឥវ៉ាន់ជាបន្ទាន់។

> *“ សូមកុំដាំបណ្តុះរុក្ខជាតិណាមួយ ដែលមើលទៅពុំមាំមួនល្អ ឬមានសត្វចង្រៃច្រើន ”*

ចូរយករុក្ខជាតិដែលមើលទៅមានជម្ងឺ ឬគំរូសត្វល្អិត ហើយដាក់វាឲ្យគេធ្វើតេស្តរោគវិនិច្ឆ័យ។ កូនរុក្ខជាតិតូចៗអាចចាំបាច់ត្រូវសំអាតបំបាត់មេរោគមុននឹងដាំវាក្នុងទីវាល។ ចូរកត់សំគាល់ថាសត្វល្អិតមួយចំនួនអាចចម្លងវ៉ាយរីស ដែលអាចចំណាយពេលពីរបីថ្ងៃ ឬសប្តាហ៍ទើបវាបង្ហាញឲ្យឃើញរោគសញ្ញា។ ទុកកន្លែងសំរាប់ពិនិត្យឆែកមើលសត្វល្អិតដែលបានជ្រើសតាំងជាពិសេស ឬទីវាលឲ្យបានស្អាត ដោយដាក់ឲ្យនៅដាច់ឆ្ងាយពីកន្លែងផលិតភោគផលរបស់លោកអ្នក សំរាប់ស្តុកទុកកូនរុក្ខជាតិតូចៗ មុននឹងយកវាទៅដាំ។ កូនរុក្ខជាតិតូចៗចាំបាច់ត្រូវទុកវាក្នុងស្នូកឈើវែង ឬធ្នើរខ្ពស់ពីដី - ចូរកុំដាក់វាទៅលើទីដីឲ្យសោះ។



> *“ ត្រូវដាក់កូនរុក្ខជាតិតូចៗទាំងអស់ឲ្យនៅដាច់ពីគេ ដើម្បីបង្ការកុំឲ្យឆ្លងរោគ និងឆែកមើលឲ្យដឹង ថាវាពុំមានសត្វចង្រៃ និងជម្ងឺឡើយ មុននឹងវាត្រូវបានគេដាំបណ្តុះ ”*

ប្រសិនបើផ្សាំបណ្តុះកូនរុក្ខជាតិតូចៗរបស់លោកអ្នកខ្លួនឯង ចូរដាក់កន្លែងផ្សាំបណ្តុះរុក្ខជាតិ ឲ្យនៅដាច់ឆ្ងាយពីកន្លែងផលិតភោគផលរបស់លោកអ្នក។ មុនពេលប្តូរកន្លែងរុក្ខជាតិណាមួយ ទៅក្នុងកន្លែងផលិតភោគផល ចូរឆែកមើលរុក្ខជាតិទាំងនោះ ដើម្បីរកមើលសញ្ញានៃសត្វល្អិតចង្រៃ ឬជម្ងឺ។ សូមកុំដាំបណ្តុះរុក្ខជាតិណាមួយដែលមាន ឬលេចចេញឡើងជាជម្ងឺ ឬមានសត្វល្អិតចង្រៃច្រើនឡើយ។

## អនាម័យរបស់បុគ្គលិក និងភ្ញៀវ

មនុស្សគឺជាមធ្យោបាយមួយ ក្នុងចំណោមមធ្យោបាយទំនងបំផុតដែលសត្វល្អិតចង្រៃ និងជម្ងឺនឹងចូលទៅក្នុងដំណាំ។ បុគ្គលិកទាំងអស់ដែលនៅលើចំការ ចាំបាច់ត្រូវទទួលខុសត្រូវ ដោយកុំនាំយកបញ្ហាដ៏មានសក្តានុផលមកក្នុងចំការឡើយ។ ចូរណែនាំបុគ្គលិកកុំឲ្យទៅទស្សនាចំការឯទៀត មុនពេលមកធ្វើការ។ ប្រសិនបើគេមកពីចំការដទៃមួយទៀត នោះគេត្រូវផ្លាស់ប្តូរសម្លៀកបំពាក់ ឬខោអៀម និងត្រូវសម្លាប់មេរោគលើដៃ ស្បែកជើងកវែង និងឧបករណ៍ទាំងអស់ មុនពេលចូលក្នុងចំការរបស់លោកអ្នក។

ភ្ញៀវដូចជាអ្នកផ្តល់ឱវាទផ្នែកកសិកម្មជាដើម ចាំបាច់ត្រូវស្គាល់អំពីសក្តានុពលរបស់គេក្នុងការដឹកជញ្ជូនសត្វចង្រៃ និងជម្ងឺ ហើយគេគួរផ្តល់ពត៌មានដល់លោកអ្នក ប្រសិនបើគេបានមកដល់ដីកម្មសិទ្ធិ ជាមួយនឹងការកើតឡើងយ៉ាងទាន់ហន់នូវសត្វចង្រៃ ឬជម្ងឺជាច្រើន។

> *“ និយោជិក និងភ្ញៀវ ជាការល្អ ពុំគួរទៅទស្សនាចំការដទៃទៀត មុនពេលចូលក្នុងចំការរបស់លោកអ្នកឡើយ ”*

សត្វល្អិតជាច្រើន ត្រូវបានទាក់ទាញដោយពណ៌ដ៏ជាក់លាក់មួយចំនួន ជាពិសេសគឺពណ៌លឿង។ អន្ទាក់ស្អិតដែលគេប្រើដើម្បីត្រួតពិនិត្យសត្វល្អិតចេះហើរ ត្រូវបានធ្វើឲ្យមានពណ៌លឿង និងពណ៌ផ្ទៃមេឃ ដោយសារមូលហេតុនេះ។ សត្វល្អិតចេះហើរជាច្រើនត្រូវបានទាក់ទាញដោយពណ៌លឿង។ សត្វល្អិតចង្រៃ Thrips ក៏ត្រូវបានទាក់ទាញយ៉ាងងាយដោយពណ៌ផ្ទៃមេឃ និងពណ៌សដែរ។ សត្វល្អិតអាចតោងឡើងជិះតាមផ្លូវបានយ៉ាងងាយ ដើម្បីចូលទៅក្នុងដំណាំ ឬតាមរយៈដំណាំដែលជាប់លើសម្លៀកបំពាក់មនុស្ស។ ដើម្បីកាត់បន្ថយហានិភ័យនៃការកើតបែបនេះ គួរជៀសវាងពណ៌លឿង ពណ៌ផ្ទៃមេឃលាយ និងពណ៌ស។ ដំណាំមាំមួនដែលដុះល្អទំនងជាអាចទប់ទល់នឹងជម្ងឺ និងពុំទាក់ទាញសត្វចង្រៃ មានប្រសិទ្ធិភាពជាងដំណាំដែលដុះអន់ខ្សោយ ឬដែលយ៉ាប់យ៉ឺនដោយសារស្ថានភាពបរិដ្ឋាន។ គឺជាការសំខាន់ដែលត្រូវយកចិត្តទុកដាក់ចំពោះសារធាតុចិញ្ចឹមសំរាប់ដំណាំ និងការបាញ់ស្រោចទឹក ដើម្បីរក្សាដំណាំឲ្យបានមាំមួន។

> *“ ត្រូវគ្រប់គ្រងការបាញ់ស្រោចទឹក និងសារធាតុចិញ្ចឹម ឲ្យបានប្រសើរបំផុត សំរាប់សេចក្តីត្រូវការរបស់រុក្ខជាតិ ”*

ថ្នាំជក់អាចនាំយកជម្ងឺខ្លះ ដែលចម្លងដល់ដំណាំលើទីវាលមួយចំនួន ជាពិសេសដំណាំអម្បូរ Solanaceous – ដូចជាប៉េងប៉ោះ ម្ទេសផ្លោកត្រប់វែង ឬម្ទេសផ្ទារជាដើម។ ប្រសិនបើនិយោជិក ឬភ្ញៀវត្រូវបានអនុញ្ញាតឲ្យជក់បារីនៅលើទីកន្លែងរបស់លោកអ្នក ចូរធ្វើឲ្យប្រាកដច្បាស់ថាគេបានលាងសំអាតដៃរបស់គេមុនពេលធ្វើការងារក្នុងដំណាំ។

បន្ទប់ទឹកដែលមានកន្លែងលាងសំអាតដៃដ៏សមស្រប ចាំបាច់ត្រូវឲ្យបុគ្គលិកចំការទាំងអស់មានលទ្ធភាពប្រើប្រាស់វាបាន។ ថ្នាំសម្លាប់មេរោគលើដៃគួរមាននៅក្នុងគ្រប់យានយន្ត រោងវេចខ្ចប់ និងបន្ទប់បុគ្គលិកទាំងអស់។ គួរលើកទឹកចិត្តដល់បុគ្គលិក និងភ្ញៀវទាំងអស់ឲ្យប្រើប្រាស់ថ្នាំសម្លាប់មេរោគលើដៃមុននឹងចាប់កាន់ដំណាំ ឬផលិតផល។

ការទទួលស្គាល់: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ បានរៀបចំចេញពី រក្សាវាឲ្យបានស្អាត – កាត់បន្ថយការចំណាយ និងការខាតបង់ក្នុងការគ្រប់គ្រងសត្វចង្រៃ និងជម្ងឺនៅក្នុងរោងដាំបន្លែ និងកូនរុក្ខជាតិ។ Badgery-Parker, J and T Burfield 2009 ជាមួយនឹងគំនិត និងឱវាទបានមកពី Sandra McDougall និង Alison Anderson។

© រដ្ឋញូវសៅវែល តាមរយៈក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ ឆ្នាំ២០១០។ លោកអ្នកអាចចម្លង ចែកចាយ និងដោះស្រាយជាមួយនឹងការបោះពុម្ពផ្សាយតាមរបៀបផ្សេងពីនេះដោយសេរី ដើម្បីគោលបំណងណាមួយ គឺឲ្យតែលោកអ្នកបានបញ្ជាក់ថាក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ គឺជាម្ចាស់កម្មសិទ្ធិនៃការបោះពុម្ពផ្សាយនេះ។

ISSN 1832-6668

ការប្រកាសមិនទទួលខុសត្រូវ: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺសំអាងលើចំណេះដឹង និងការយល់ដឹងនៅក្នុងពេលកំពុងសរសេរ (ខែមីនា ឆ្នាំ២០១២)។ ទោះជាយ៉ាងនេះក្តី ដោយសារការជឿនលឿនផ្នែកចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកអំពីសេចក្តីត្រូវការដើម្បីឲ្យប្រាកដច្បាស់ថា ពត៌មានដែលគេពឹងផ្អែកទៅលើ មានលក្ខណៈទាន់ពេល និងសំរាប់ឆែកមើលបច្ចុប្បន្នភាពនៃពត៌មានជាមួយភ្នាក់ងារសមស្របរបស់ក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ឬអ្នកផ្តល់ឱវាទឯករាជ្យសំរាប់អ្នកប្រើប្រាស់។

ចុះផ្សាយដោយក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ដែលជាផ្នែកមួយរបស់ក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ។

Trim reference INT 12/24534

Horticulture Australia

ការផលិតប័ណ្ណពត៌មាននេះ និងការបកប្រែភាសាបានទទួលការផ្គត់ផ្គង់ប្រាក់មួយ ចំណែកពីគំរោងដែលទទួលប្រាក់ឧបត្ថម្ភរបស់ HAL អង្គការដំណាំវប្បកម្មអូស្រ្តាលី): *ការដោះស្រាយអំពីគុណភាព និងសុវត្ថិភាពនៃផលិតផលជាមួយអ្នកដាំដុះនៃឧស្សាហកម្មបន្លែដែលនិយាយភាសាក្រៅពីភាសាអង់គ្លេស* ការផ្តើមគំនិតនៃកម្មវិធីអភិវឌ្ឍន៍ឧស្សាហកម្មបន្លែ។